EDITORS:
Chia Poh Fang, Amos Khan,
Khan Hui Neon, Leslie Koh

DESIGN & LAYOUT: Felix Xu

COVER & CONTENT PHOTOS:
ShutterStock.com

រក្សាសិទ្ធិគ្រប់យ៉ាងដោយ: © 2017 ODB Ministries ( website: www.odb.org )

បទគម្ពីរជាភាសាខ្មែរដកស្រង់ចេញពី ព្រះគម្ពីរបរិសុទ្ធ ភាសាខ្មែរ បកប្រែចាស់ ឆ្នាំ១៩៥៤ ដោយការអនុញ្ញាតិ និង រក្សាសិទ្ធិដោយសមាគមន៍ព្រះគម្ពីរ សកល ( បានដកស្រង់ ដោយរក្សាអក្ខរាវិរុទ្ធដើម )។

# រឿង

# នៃសេចក្តីសង្ឃឹម

## បើសិនជា

បើសិនជា   លោកិយមានភាពល្អឥតខ្ចោះ។ បើសិនជាពិភពលោក គ្មានការអាក្រក់ ជម្ងឺ និងគ្រោះធម្មជាតិទេនោះ។ បើសិនជាយើងរាល់គ្នាសុទ្ធតែអាចរស់នៅ ក្នុងសន្តិភាព ដោយគ្មានជម្លោះនៅក្នុងក្រុមគ្រួសារ និងសហគមន៍ទេនោះ។ បើសិនជាយើងមិនចាំបាច់ត្រូវព្រួយបារម្ភអំពីចំណីអាហារ សំលៀកបំពាក់ និងជម្រក ឬមិនចាំបាច់ត្រូវខ្លាចបាត់បង់ការងារ និងសមត្ថភាព នៅក្នុងការផ្គត់ផ្គង់ក្រុមគ្រួសាររបស់យើងទេនោះ។

### តែគួរឲ្យស្តាយណាស់ លោកិយស្ថិតនៅឆ្ងាយយ៉ាងខ្លាំង ពីភាពល្អឥតខ្ចោះ។

មានបញ្ហាជាច្រើនសណ្ឋិក ដែលកំពុងកើតឡើង នៅជុំវិញយើង។ បញ្ហាខ្លះជារឿងធម្មជាតិ ហើយបញ្ហាជាច្រើនទៀត ត្រូវបានបង្ករឡើងដោយមនុស្ស។ យើងកំពុងរស់នៅ ក្នុងលោកិយដែលមានពេញ ដោយការប៉ះទង្គិច និងវិបត្តិផ្សេងៗ ហើយជារៀងរាល់ថ្ងៃ យើងឃើញពត៌មានផ្សាយអំពីសង្គ្រាម ឧក្រិដ្ឋកម្ម ជម្ងឺរាតត្បាត គ្រោះធម្មជាតិ និងវិបត្តិសេដ្ឋកិច្ច។

យើងក៏ជួបប្រទះបញ្ហានៅក្នុងជីវិតផ្ទាល់ខ្លួនផងដែរ។ អ្នកខ្លះកំពុងជួបការពិបាក នៅក្នុងទំនាក់ទំនង ការមានជម្ងឺ ឬការញៀណថ្នាំជាដើម។ ពុំនោះទេ យើងប្រហែលជាត្រូវបានគ្របសង្កត់ ដោយការព្រួយបារម្ភចំពោះបញ្ហាដែលកើតមានជាក់ស្តែង ការទទួលខុសត្រូវធ្ងន់ៗ និងការ



ប្តេជ្ញាចិត្តដែលនាំឲ្យមានបន្ទុកធ្ងន់។ គឺស្ថិតក្នុងពេលនោះហើយ ដែលយើងឆ្ងល់ថា "ហេតុអ្វីលោកិយ មានបញ្ហាជាច្រើនយ៉ាងនេះ? ហេតុអ្វីការរស់នៅ មានការពិបាកយ៉ាងនេះ? ហេតុអ្វីជីវិតខ្ញុំ មិនអាចមានភាពងាយស្រួលជាងនេះ?"

ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ យើងដឹងផងដែរថា ពិភពលោកអាចមានភាពល្អប្រសើរជាងមុន។ យើងមើលឃើញភាពល្អឥតខ្ចោះ និងសេចក្តីល្អ នៅជុំវិញយើង ក្នុងរយៈពេលខ្លី។ យើងបានអានអត្ថបទដែលនិយាយ អំពីពេលដ៏សុខសាន្ត និងឮគេនិយាយ អំពីមនុស្សដែលរស់នៅក្នុងជីវិតដ៏សប្បាយ និងគ្មានបញ្ហា ពុំនោះទេ យើងប្រហែលជាធ្លាប់បានពិសោធន៍ នឹងសុភមង្គលយ៉ាងនេះពីមុនមក។ យើងដឹងថា អ្វីៗអាចមានភាពល្អប្រសើរជាងមុន តែបើក្នុងពេលបច្ចុប្បន្ន យើងមិនឃើញមានអ្វីល្អជាងមុនសោះ តើយើងនឹងមានចិត្តតប់ប្រមល់ប៉ុណ្ណា?

ប្រហែលមូលហេតុនេះហើយ បានជាអ្នកគួរតែអានកូនសៀវភៅនេះ។ និយាយរួម អ្វីដែលយើងត្រូវការ គឺសេចក្តីសង្ឃឹម។ យើងសង្ឃឹមថា យើងនឹងមានផ្លូវគេចចេញពីបញ្ហា សង្ឃឹមថា យើងនឹងមានដំណោះស្រាយសម្រាប់បញ្ហាយើង និងសង្ឃឹមថា នឹងមានជីវិតល្អជាងមុន។

## ការស្វែងរកសេចក្តីសង្ឃឹម

សូមអនុញ្ញាត ឲ្យយើងខ្ញុំចែករំលែករឿងមួយ ដែលអាចឆ្លើយតបនឹងសំណួរខាងលើ ហើយក៏បានផ្តល់ឲ្យយើង នូវក្តីសង្ឃឹមផងដែរ។ អ្នកមិនចាំបាច់ត្រូវយល់ស្របនឹងអ្វីគ្រប់យ៉ាង ដែលយើងខ្ញុំនឹងនិយាយឡើយ សូមចំណាយពេលតែពីរបីនាទី ដើម្បីអាន និងពិចារណា អំពីអ្វីដែលយើងខ្ញុំនឹងចែកចាយ នៅទំព័របន្ទាប់។ សរុបមក មានតែអ្នកទេ ដែលអាចវាយតម្លៃដោយខ្លួនឯង ថាតើអ្វីដែលយើងខ្ញុំចែកចាយ មានន័យសម្រាប់អ្នកឬអត់ ទោះបីជាយើងខ្ញុំបានជឿអស់ពីចិត្តថា ការសម្រេចចិត្តរបស់អ្នក អាចនាំមកនូវភាពខុសប្លែកដ៏ធំ ក្នុងជីវិតអ្នកក៏ដោយ។

***និយាយឲ្យខ្លីអ្វីដែលយើងត្រូវការនោះ គឺសេចក្តីសង្ឃឹម។***

នៅទំព័រដើម យើងបានសួរខ្លួនឯងថា ហេតុអ្វីពិភពលោកនេះ មានបញ្ហាច្រើនយ៉ាងនេះ? មនុស្សជាច្រើនជឿថា ភាពពុកផុយ គឺជាដំណើរនៃធម្មជាតិ ដែលក្នុងនោះ អ្វីៗគ្រប់យ៉ាងត្រូវអន់ថយ ទៅរកភាពខូតខាត នៅទីបញ្ចប់ ដោយជៀសមិនផុត។ ទស្សនៈនេះ គឺស្របនឹងទ្រឹស្តីវិទ្យាសាស្ត្រ ដែលបានអះអាងថា ចក្រវាលត្រូវបានបង្កើតឡើង ដោយសារបាតុភូតិធម្មជាតិ ដែលជាបន្ទុះដ៏ធំបំផុត គេហៅថា ប៊ីក ប៊ែង ហើយមនុស្សជាតិកើតចេញពីដំណើរនៃការវិវត្តន៍ ដែលជាដំណើរនៃធម្មជាតិ។ អ្នកខ្លះទៀតបានជឿថា លោកិយប្រហែលជាត្រូវបានបង្កើតឡើង ដោយអំណាចរបស់ព្រះមួយអង្គ ឬអង្គបុគ្គលដែលមានលក្ខណៈអធិធម្មជាតិ ប៉ុន្តែ ក្រោយមក ទ្រង់ក៏បានទុកឲ្យផែនដីបន្តដំណើរការទៅមុខទៀត ដោយច្បាប់ធម្មជាតិ ដោយគ្មាន

ការរំខានពីទ្រង់។

ប៉ុន្តែ ព្រះគម្ពីរដែលជាគោលនៃជំនឿរបស់គ្រីស្ទបរិស័ទ មានការបកស្រាយផ្សេងពីនេះ។ ព្រះគម្ពីរបានចែងថា ព្រះពិតមានតែមួយប៉ុណ្ណោះ ហើយទ្រង់បានបង្កើតចក្រវាល និងផែនដី និងសត្វដែលមានជីវិតទាំងអស់ ព្រមទាំងជីវិតមនុស្សផងដែរ។ ប៉ុន្តែ រឿងនៃការបង្កើតរបស់ព្រះដែលមានចែងក្នុងព្រះគម្ពីរ មិនមែនមានតែប៉ុណ្ណោះទេ។ ព្រះដ៏ជាព្រះអាទិករ ក៏សព្វព្រះទ័យនឹងមានការប្រកបទាក់ទងជាមួយមនុស្សជាតិផងដែរ។ ព្រោះបន្ទាប់ពីទ្រង់បានបង្កើតមនុស្សជាតិ ទ្រង់បានបន្តមានទំនាក់ទំនងជាមួយពួកគេ ហើយថែរក្សាពួកគេ។ ទ្រង់បានដាក់មនុស្សប្រុស និងមនុស្សស្រីដំបូងបំផុត គឺអ័ដាំម និងនាងអេវ៉ា ក្នុងសួនច្បារដ៏ស្រស់ស្អាតមួយ ដោយមានរបស់ល្អជាច្រើន ដែលពួកគេអាចបរិភោគជាអាហារ ហើយបានអនុញ្ញាតឲ្យពួកគេ ទៅមកដោយសេរីនៅក្នុងសួនច្បារនោះ ហើយទ្រង់បានជួប និងមានបន្ទូលជាមួយពួកគេជាញឹកញាប់។

តើហេតុអ្វី? ព្រោះព្រះទ្រង់បានបង្កើតយើងមក ដើម្បីឲ្យមានទំនាក់ទំនងនៃសេចក្តីស្រឡាញ់ ជាមួយទ្រង់។ ព្រះទ្រង់សព្វព្រះទ័យនឹងឲ្យយើងរស់នៅក្នុងព្រះវត្តមានទ្រង់ គឺមិនខុសពីឪពុកម្តាយ ដែលមានកូនដែលចង់នៅក្បែរកូនរបស់ខ្លួននោះឡើយ។ ហេតុនេះហើយ បានជាទ្រង់បានបង្កើតមនុស្សមក ឲ្យមានអារម្មណ៍ និងមនោសញ្ចេតនា ហើយមាន



**ព្រះគម្ពីរបានចែងថា ព្រះពិតមានតែមួយប៉ុណ្ណោះ ហើយទ្រង់បានបង្កើតចក្រវាល និងផែនដី និងសត្វដែលមានជីវិតទាំងអស់ ព្រមទាំងជីវិតមនុស្សផងដែរ។**

បំណងចិត្ត និងសមត្ថភាពស្រឡាញ់ និងទទួលក្តីស្រឡាញ់ ដែលទាំងនេះ សុទ្ធតែបានឆ្លុះបញ្ចាំង អំពីចារិកលក្ខណៈរបស់ព្រះ។ ដើម្បីឲ្យយើងអាចមានសេចក្តីស្រឡាញ់ដ៏ពិត យើងចាំបាច់ត្រូវប្រព្រឹត្តឲ្យត្រឹមត្រូវ សមស្របនឹងក្តីស្រឡាញ់។ ហេតុនេះហើយ បានជាព្រះទ្រង់បង្កើតមនុស្សប្រុស និងមនុស្សស្រីមក ឲ្យមានសភាវគតិ ដែលនាំឲ្យធ្វើអ្វីដែលត្រឹមត្រូវ និងមានសីលធម៌ ដែលឆ្លុះបញ្ចាំងឲ្យឃើញលក្ខណៈ ដ៏ល្អបរិសុទ្ធ និងយុត្តិធម៌របស់ព្រះ។

ដោយសារព្រះទ្រង់ល្អ នោះលោកិយដែលទ្រង់បានបង្កើត ក៏ល្អពីដំបូងផងដែរ។ មនុស្សជាតិមានទំនាក់ទំនងដ៏ល្អជាមួយទ្រង់ និងជាមួយមនុស្សដូចគ្នា ហើយមិនចាំបាច់ត្រូវព្រួយបារម្ភ អំពីជម្ងឺ ឬការស្លាប់ឡើយ។

បន្ទាប់មក អ្វីៗគ្រប់យ៉ាងនៅលើផែនដីមានបញ្ហា។

## អំពើបាបបានចាប់ផ្តើមចូលក្នុងលោកិយ

ឪពុកម្តាយដែលល្អ ចង់ឲ្យកូនខ្លួន ស្រឡាញ់ខ្លួនវិញ ដោយស្ម័គ្រពីចិត្តមិនមែនស្រឡាញ់ ដោយសារនោះជាកាតព្វកិច្ច ឬដោយសារការបង្ខិតបង្ខំនោះឡើយ។ ទំនាក់ទំនងរវាងឪពុកម្តាយនិងកូន មានភាពល្អប្រសើរទៅបាន ទាល់តែទាំងសង្ខាងបានសម្រេចចិត្តស្រឡាញ់គ្នា ទៅវិញទៅមក។ ទោះជាយ៉ាងណាក៏ដោយ ពួកគេបង្ហាញចេញសេចក្តីស្រឡាញ់របស់ខ្លួន តាមរបៀបផ្សេងគ្នា។ ឪពុកម្តាយ បង្ហាញសេចក្តីស្រឡាញ់ខ្លួនដល់កូន ដោយការចិញ្ចឹមបីបាច់ ការពារ និងថែរក្សាកូនរបស់ខ្លួន ហើយចំណែកកូនវិញ ស្រឡាញ់ឪពុកម្តាយ ដោយស្តាប់បង្គាប់ពួកគាត់ ហើយធ្វើអ្វីដែលពួកគាត់សប្បាយចិត្ត។

*ព្រះទ្រង់សព្វព្រះទ័យឲ្យពួកគេស្រឡាញ់ទ្រង់ ដោយស្ម័គ្រពីចិត្ត។*

នេះជាប្រភេទនៃទំនាក់ទំនង ដែលព្រះទ្រង់សព្វព្រះទ័យនឹងមាន ជាមួយយើង។ ពេលទ្រង់បង្កើតអ័ដាំម និងនាងអេវ៉ា ទ្រង់បានឲ្យពួកគេមានសុភាវគតិ ដែលចង់ធ្វើជាមនុស្សល្អ ប៉ុន្តែ ដែលសំខាន់បំផុតនោះ គឺទ្រង់បានប្រទានឲ្យពួកគេមានសេរីភាព នៅក្នុងការសម្រេចចិត្ត គឺមានន័យថា ពួកគេអាចសម្រេចចិត្តស្រឡាញ់ទ្រង់ ឬមិនស្រឡាញ់ទ្រង់វិញក៏បាន។ ទ្រង់សព្វព្រះទ័យឲ្យពួកគេស្រឡាញ់ទ្រង់ ដោយស្ម័គ្រពីចិត្ត។ ក្នុងសួនច្បារដែលពួកគេរស់នៅ ទ្រង់បានប្រទានឲ្យពួកគេមានជម្រើសបែបនេះ ដោយទ្រង់ដាក់ដើមឈើមួយដើម ក្នុងសួនច្បារនោះ។ ព្រះទ្រង់បានប្រាប់អ័ដាំម និងនាងអេវ៉ាយ៉ាងច្បាស់ថា ពួកគេអាចបរិភោគផ្លែឈើ ដែលបេះពីដើមឈើណាក៏បាន លើកលែងតែដើមឈើមួយដើមនោះ ដូចនេះ ពួកគេត្រូវសម្រេចចិត្តស្តាប់បង្គាប់ ឬមិនស្តាប់បង្គាប់ព្រះ។

គួរឲ្យស្តាយណាស់ ពួកគេបានសម្រេចចិត្តមិនស្តាប់បង្គាប់ព្រះអាទិកររបស់ពួកគេ។ ពួកគេបានបរិភោគផ្លែឈើនោះ និយាយរួម ពួកគេបាន

ប្រព្រឹត្តអ្វីដែលព្រះទ្រង់បានហាម មិនឲ្យពួកគេធ្វើ។ (មនុស្សជាច្រើនចូលចិត្តគិតថា ផ្លែឈើនោះ គឺជាផ្លែប៉ោម ប៉ុន្តែ ព្រះគម្ពីរមិនបានប្រាប់យើងថា ផ្លែនោះជាផ្លែប៉ោមទេ)។ ព្រះបានព្រមានពួកគេថា បើពួកគេបរិភោគផ្លែឈើនោះ ពួកគេនឹងស្លាប់មិនខានទេ។ ប៉ុន្តែ ពួកគេនៅតែមិនស្តាប់បង្គាប់ទ្រង់។ ដូចនេះ អ័ដាំម និងនាងអេវ៉ាបាននាំអំពើបាប ចូលទៅក្នុងលោកិយ។

អំពើបាប គឺជា "ការខ្វះមិនដល់" គឺខ្វះមិនដល់ស្តង់ដា ឬខ្នាតគំរូដ៏ល្អឥតខ្ចោះរបស់ព្រះ។ ពេលដែលអ័ដាំម និងនាងអេវ៉ានៅស្តាប់បង្គាប់ព្រះទ្រង់សព្វព្រះទ័យនឹងពួកគេ។ ប៉ុន្តែ ពេលដែលពួកគេមិនស្តាប់បង្គាប់ទ្រង់ ដោយបរិភោគផ្លែឈើនោះ មានន័យថា ពួកគេបានបដិសេធន៍សិទ្ធិអំណាចរបស់ព្រះ។ អ្វីដែលកាន់តែអាក្រក់ជាងនេះទៀតនោះ  គឺការសម្រេចចិត្តរបស់ពួកគេ មិនគ្រាន់តែមានផលប៉ះពាល់មកលើខ្លួនឯងប៉ុណ្ណោះទេ ប៉ុន្តែ ក៏បានប៉ះពាល់កូនចៅជំនាន់ក្រោយនៃមនុស្សជាតិផងដែរ។ កូនចៅរបស់អ្នកទាំងពីរក៏បានបន្តសន្តាននៃការបះបោររបស់ឪពុកម្តាយខ្លួន ដោយធ្វើអ្វីតាមចិត្តខ្លួន គឺមិនមែនធ្វើតាមខ្នាតគំរូដ៏ឥតខ្ចោះរបស់ព្រះទេ។ មនុស្សជាតិចាប់ផ្តើមធ្វើអ្វី ដែលមិនត្រឹមត្រូវ ខុសសីលធម៌ ខណៈពេលដែលពួកគេគិតថា ពួកគេមិនចាំបាច់ត្រូវរៀបរាប់ថ្វាយព្រះ អំពីអ្វីដែលខ្លួនបានប្រព្រឹត្តឡើយ។

*ពេលដែលពួកគេមិនស្តាប់បង្គាប់ទ្រង់ ដោយបរិភោគផ្លែឈើនោះ មានន័យថា ពួកគេបានបដិសេធន៍សិទ្ធិអំណាចរបស់ព្រះ។*

ជាលទ្ធផល មនុស្សជាតិបានបំផ្លាញទំនាក់ទំនងដ៏ឥតខ្ចោះដែលខ្លួនមានជាមួយព្រះ និងជាមួយមនុស្សដូចគ្នា គឺមិនខុសពីកូនមិនស្តាប់បង្គាប់ ដែលបន្តបះបោរ និងដកខ្លួនចេញឆ្ងាយពីឪពុកម្តាយខ្លួននោះទេ។ ពួកគេបានងាកបែរចេញពីព្រះកាន់តែឆ្ងាយទៅៗ។ ទោះទ្រង់នៅតែបន្តស្រឡាញ់ពួកគេក៏ដោយ ក៏ពួកគេនៅតែបដិសេធន៍មិនព្រមចូលទៅជិតទ្រង់។

សព្វថ្ងៃនេះ យើងឃើញភស្តុតាងនៃការបាក់បែកនេះ ក្នុងទំនាក់ទំនងបាក់បែក ដែលយើងមានជាមួយព្រះ និងជាមួយមនុស្សដូចគ្នា។ យើងមិនបានទទួលសេចក្តីស្រឡាញ់ និងការទុកចិត្តទេ ផ្ទុយទៅវិញ យើងបានពិសោធន៍នឹងការភ័យខ្លាច កំហឹង សេចក្តីសំអប់ និងភាពល្ងីងល្ងើចត់។ យើងឃើញមនុស្សបះបោរប្រឆាំងនឹងព្រះ និងទម្រង់នៃការដឹកនាំ និងសិទ្ធិអំណាចដទៃទៀត ហើយក៏ឃើញមនុស្សស្អប់គ្នា ហើយធ្វើបាបគ្នា។

សេចក្តីស្លាប់ គឺជាលទ្ធផលមួយទៀតនៃអំពើបាប ដែលកើតឡើងពីការបរិភោគផ្លែឈើដែលព្រះបានហាម។ ព្រះទ្រង់បានព្រមានអ័ដាំម និងនាងអេវ៉ាថា បើពួកគេបរិភោគផ្លែឈើ ពីដើមឈើនោះ ពួកគេនឹងស្លាប់មិនខាន។ ហេតុអ្វីបានជាទ្រង់ព្រមានពួកគេ? ព្រោះទ្រង់ជ្រាបថា ពេលដែលពួកគេសម្រេចចិត្តបះបោរប្រឆាំងនឹងទ្រង់ គឺមានន័យថា ពួក



**សេចក្ដីស្លាប់ គឺជាលទ្ធផលមួយទៀតនៃអំពើបាប ដែលកើតឡើងពីការបរិភោគផ្លែឈើដែលព្រះបានហាម។**

គេបានបំផ្លាញការប្រកបទាក់ទងដ៏ឥតខ្ចោះ ដែលពួកគេធ្លាប់មានជាមួយទ្រង់ ហើយផ្ដាច់ខ្លួនចេញពីទ្រង់ ដែលជាប្រភពនៃជីវិតអស់កល្ប។ ទង្វើរនេះមិនខុសពីការដកឌុយរបស់ឧបករណ៍អេឡិចត្រូនិច ចេញពីប្រភពអគ្គីសនី ដែលធ្វើឲ្យពួកគេបាត់បង់អំណាច ឬថាមពល។

ការស្លាប់នេះ គឺជាការស្លាប់ទាំងរូបកាយ និងវិញ្ញាណ។ ដោយសារយើងជាជីវិតដែលមានរូបកាយ ដែលទទួលផលប៉ះពាល់ពីអំពើបាប រូបកាយយើងមិនមានភាពឥតខ្ចោះទៀត បានជាវាត្រូវខូចខាត និងអន់ខ្សោយបន្ដិចម្ដងៗ ហើយក៏ត្រូវស្លាប់។ ប៉ុន្តែ ដោយសារយើងក៏ជាជីវិតខាងវិញ្ញាណ យើងមានវិញ្ញាណផងដែរ ហើយវិញ្ញាណនោះក៏ត្រូវកាត់ផ្ដាច់ចេញពីព្រះអស់កល្បជានិច្ច។ ដោយសារយើងបះបោរ ហើយមានបាប ហើយមិនអាចវិលត្រឡប់មកព្រះវត្តមាន នៃព្រះដ៏បរិសុទ្ធ យុត្តិធម៌ និងសុចរិតបានឡើយ។ យើងក៏ត្រូវទទួលខុសត្រូវ ចំពោះអំពើបាបរបស់យើងផងដែរ គឺមិនខុសពីការដែលព្រះទ្រង់បានឲ្យអ័ដាំម និងនាងអេវ៉ាទទួលខុសត្រូវ ចំពោះការសម្រេចចិត្តរបស់ពួកគេ ក្នុងសួន ច្បារនោះឡើយ។ នេះគឺជាច្បាប់ ឬក្រឹត្យវិន័យ ដែលទ្រង់បានដាក់ឲ្យមនុស្សជាតិ។

ការបាក់បែកទំនាក់ទំនងនេះ ក៏មានផលប៉ះពាល់ដល់ការរស់នៅរបស់យើង ក្នុងពេលបច្ចុប្បន្នផងដែរ។ យើងមានអារម្មណ៍ថា យើងកំពុងរស់នៅដោយគ្មានគោលបំណង ឬគោលដៅ និងក្តីសង្ឃឹម គឺដូចជាមនុស្សដែលវង្វេង។ មនុស្សជាច្រើនបានឆ្លងកាត់ជីវិត ដោយភាពអស់សង្ឃឹម។ យើងប្រហែលជាមិនដឹងច្បាស់ថា ហេតុអ្វីយើងមានភាពអស់សង្ឃឹមទេ តែក្នុងជម្រៅចិត្តយើង យើងមានអារម្មណ៍ថា មានការបាត់បង់ ដែលជាលទ្ធផលនៃការដាច់ចេញពីព្រះ។ ជីវិតយើងហាក់ដូចជាគ្មានគោលបំណង និងគ្មានន័យឡើយ ព្រោះយើងបានដាច់ចេញពីប្រភពដ៏ពិតនៃជីវិត។

នេះជាបញ្ហាដែលលោកិយ កំពុងតែជួបប្រទះសព្វថ្ងៃ។ ព្រះបានបង្កើតពិភពលោកឲ្យមានភាពល្អឥតខ្ចោះ ប៉ុន្តែ អ័ដាំមនិងនាងអេវ៉ា បានសម្រេចចិត្តធ្វើអំពើបាប ហើយជាលទ្ធផល ពួកគេត្រូវកាត់ផ្តាច់ចេញពីព្រះ ហើយត្រូវទទួលខុសត្រូវ ចំពោះសកម្មភាព និងគំនិតរបស់ខ្លួន។ សព្វថ្ងៃនេះ យើងក៏ធ្វើដូចពួកគេផងដែរ ព្រោះយើងបានបដិសេធព្រះ ហើយប្រឆាំងនឹងខ្នាតគំរូដ៏ល្អឥតខ្ចោះរបស់ទ្រង់ បានជាយើងក៏នឹងទទួលលទ្ធផល ពីទង្វើរបស់យើងផងដែរ។ ត្រង់ចំណុចនេះ ព្រះគម្ពីរបានចែងច្បាស់ថា "ពីព្រោះគ្រប់គ្នាបានធ្វើបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ" ហើយ "ដ្បិតឈ្នួលរបស់អំពើបាប នោះជាសេចក្តីស្លាប់"(រ៉ូម ៣:២៣ ៦:២៣)។



តើការនេះមានន័យថា យើងត្រូវចប់ហើយមែនទេ? តើយើងអាចមានដំណោះស្រាយអ្វីទេ?

# ដំណោះស្រាយ

ចាប់តាំងពីពេលដែលមនុស្សជាតិបានដាច់ចេញពីព្រះមក យើងបានព្យាយាមដោះស្រាយបញ្ហានៃអំពើបាប និងលទ្ធផលនៃអំពើបាប។ យើងបានព្យាយាមការពារមិនឲ្យមានជម្ងឺ និងពន្យាជីវិត ដោយប្រើវិទ្យាសាស្ត្រ និងថ្នាំពេទ្យជាដើម។ យើងបានព្យាយាមធ្វើឲ្យសង្គម មានភាពត្រឹមត្រូវ តាមក្រមសីលធម៌ ដោយអនុវត្តច្បាប់ផ្សេងៗ ហើយបង្រៀនមនុស្ស ឲ្យមានអាកប្បកិរិយា ដែលមានសីលធម៌។ យើងបានព្យាយាមទប់ស្កាត់មិនឲ្យមានជម្លោះ និងសង្គ្រាម ហើយព្យាយាមទ្រទ្រង់សន្តិភាព និងការរួបរួម ក្នុងចំណោមអ្នកជិតខាង សហគមន៍ និងប្រជាជាតិទាំងឡាយ។ ហើយយើងក៏បានព្យាយាមកាត់បន្ថយកំហុស និងផ្គាប់ចិត្តព្រះ ដោយខំធ្វើការល្អ និងធ្វើតាមក្រឹត្យវិន័យរបស់សាសនា។

ប៉ុន្តែ ដូចដែលយើងអាចមើលដឹង យើងពិតជាមិនបានទទួលជោគជ័យក្នុងការខិតខំទាំងអស់នេះទេ មែនទេ? យើងពិតជាមិនអាចគាំពារមិនឲ្យមានជម្ងឺ និងសេចក្តីស្លាប់ ឬការពារមិនឲ្យមនុស្សធ្វើខុសច្បាប់ ឬធ្វើសង្គ្រាមឡើយ។ មនុស្សជាច្រើននៅតែព្យាយាមស្វែងរកអត្ថន័យនៃជីវិត។ យើងមិនខុសពីមនុស្សវង្វេង ដែលស្វែងរកសេចក្តីស្រឡាញ់ និងសុវត្ថិភាព ទាំងងងឹតងងល់ឡើយ។

ហេតុអ្វី? ពីព្រោះ សរុបមក ចិត្តរបស់យើង មិនល្អឥតខ្ចោះទេ។ យើងបានបាត់សមត្ថភាពធ្វើការល្អឲ្យបានជាប់ជាប្រចាំ និងឲ្យបានឥតខ្ចោះ ទោះបីជាយើងបានព្យាយាមខ្លាំងយ៉ាងណាក៏ដោយ។ សូម្បីតែនៅពេលដែលយើងចង់ធ្វើជាមនុស្សល្អ ក៏យើងហាក់ដូចជាទទួលការអូសទាញទៅរកការអាក្រក់ ជាធម្មតាទៅហើយ។ យើងងាយនឹងមានកំហឹង និងការសងសឹក ជាជាងមានការអត់ទោស និងមានក្តីអាណិត។ និស្ស័យសាច់ឈាមយើងចេះតែឲ្យយើងធ្វើអ្វីៗ តាមសេចក្តីប៉ងប្រាថ្នារបស់យើង ហើយគិតប្រយោជន៍ខ្លួនឯងជាទីមួយ ជាជាងគិតពីប្រយោជន៍អ្នកដទៃ។

> *សូម្បីតែនៅពេលដែលយើងចង់ធ្វើជាមនុស្សល្អ ក៏យើងហាក់ដូចជាទទួលការអូសទាញទៅរកការអាក្រក់ ជាធម្មតាទៅហើយ។*

តើបញ្ហាទាំងនេះកើតឡើងដោយរបៀបណា? ជាការពិតណាស់ អំពើបាបមានអំណាចគ្រប់គ្រងមកលើយើង គឺដូចជាការញៀនថ្នាំអញ្ចឹងដែរ។ វាគ្រប់គ្រងយើង ហើយបង្ខំយើងឲ្យបន្តធ្វើខុស សូម្បីតែនៅពេលដែលយើងមិនចង់ធ្វើក៏ដោយ។ អំពើបាបមានឥទ្ធិពលមកលើការសម្រេចចិត្ត និងសកម្មភាពយើង ហើយនាំឲ្យយើងកាន់តែពិបាកធ្វើអ្វីដែលត្រឹមត្រូវ ហើយកាន់តែងាយស្រួលធ្វើខុស។ យើងកាន់តែងាយបះបោរប្រឆាំងនឹងព្រះ ជាជាងស្តាប់បង្គាប់ទ្រង់។

ដូចនេះ តើយើងអាចកែប្រែចិត្តយើងដោយរបៀបណា? តើធ្វើដូចម្ដេចឲ្យយើងអាចផ្សះផ្សារឲ្យជានឹងព្រះវិញ ពេលដែលអំពើបាបចេះតែរារាំងយើង មិនឲ្យធ្វើការល្អ ឲ្យបានជាទៀតទាត់នោះ? យើងមិនអាចធ្វើដោយខ្លួនឯងបានទេ។ ប៉ុន្តែ ព្រះទ្រង់អាច។

ទ្រង់អាចកែប្រែចិត្តយើងបាន ព្រោះទ្រង់ជាព្រះអាទិករ ហើយគ្រប់គ្រងលើអ្វីៗគ្រប់យ៉ាង។ មានតែព្រះទេ ដែលអាចលាងសម្អាតស្នាមប្រឡាក់យើងឲ្យស្អាត ហើយលប់ដាននៃអំពើបាបយើងឲ្យអស់ ដើម្បីឲ្យយើងអាចផ្សះផ្សាជាមួយទ្រង់ ហើយរស់នៅដោយសុខុដមទាំងស្រុង ជាមួយទ្រង់។ មានតែទ្រង់ទេ ដែលអាចស្អាងចិត្តយើងឲ្យល្អឡើងវិញ ដើម្បីកុំឲ្យយើងស្ថិតនៅក្រោមការគ្រប់គ្រងនៃអំពើបាប និងសេចក្ដីស្លាប់ទៀតឡើយ។ ទ្រង់អាចជួយយើងបាន ប៉ុន្តែ តើទ្រង់សព្វព្រះទ័យនឹងជួយយើងទេ?

អ្វីដែលអស្ចារ្យនោះគឺ ព្រះទ្រង់សព្វព្រះទ័យឲ្យយើងផ្សះផ្សារឲ្យជានឹងទ្រង់វិញ។ ជាការពិតណាស់ ទោះមនុស្សជាតិមិនព្រមស្ដាប់បង្គាប់ទ្រង់ ហើយបានបន្ដបះបោរប្រឆាំងនឹងទ្រង់ក៏ដោយ ក៏ព្រះទ្រង់នៅតែសព្វព្រះទ័យនឹងផ្សះផ្សាមនុស្សជាតិ ឲ្យជានឹងទ្រង់វិញ។ សូមយើងចាំថា ព្រះទ្រង់មានលក្ខណៈដូចជាឪពុកម្ដាយដែលស្រឡាញ់ ហើយយកចិត្តទុកដាក់ចំពោះកូនខ្លួន។ ទ្រង់ជាឪពុកម្ដាយដែលមិនដែលឈប់ស្រឡាញ់កូនសំណព្វចិត្តរបស់ខ្លួនទេ ទោះកូនទ្រង់បានរត់ចេញទៅឆ្ងាយ ហើយមិនទទួលស្គាល់ទ្រង់ជាឪពុកម្ដាយទៀតក៏ដោយ។ ដោយសារទ្រង់ជាព្រះដែលមានព្រះទ័យមេត្តា នោះទ្រង់សព្វព្រះទ័យនឹងអត់ឱនទោសឲ្យយើង ហើយទទួលស្វាគមន៍យើង ឲ្យវិលត្រឡប់មកក្នុងរង្វង់ដៃទ្រង់វិញ។

ប៉ុន្តែ មានបញ្ហាមួយ។ យើងដឹងហើយថា ព្រះទ្រង់មានភាពសុចរិត ហើយបរិសុទ្ធ។ ទ្រង់មិនអាចធ្វើជាមិនឃើញអំពើបាបយើង ហើយមានបន្ទូលថា "បំភ្លេចវាចោលចុះ។ វាមិនអីទេ"។ ទ្រង់មិនអត់ឱនឲ្យអំពើបាបយើង ហើយមិនអាចធ្វើជាមិនខ្វល់ ហាក់ដូចជាយើងមិនបានប្រព្រឹត្តអំពើបាបនោះទេ។ បើព្រះទ្រង់មិនខ្វល់ពីអំពើបាបយើងទេ នោះមានន័យថា ទ្រង់បានក្បត់នឹងលក្ខណៈរបស់ទ្រង់ ដែលជាព្រះដែលល្អ និងបរិសុទ្ធហើយ។

ហេតុនេះហើយ បានជាទ្រង់សព្វព្រះទ័យនឹងរំដោះយើង ឲ្យរួចពីអំណាចអំពើបាបដែលគ្រប់គ្រងជីវិតយើង ប៉ុន្តែ ជាក្នុងនាមទ្រង់ជាព្រះដែលសុចរិត និងបរិសុទ្ធ ទ្រង់មិនអាចឲ្យយើងរួចពីទោស ដែលយើងសក្ដិសមនឹងទទួល ចំពោះអំពើបាបដែលយើងមាននោះទេ។ ទោះជាយ៉ាងណាក៏ដោយ ទ្រង់បានប្រទាននូវផ្លូវមួយ ដើម្បីឲ្យយើងអាចរួចពីបាប។




# ឲ្យយើងរួចពីសេចក្តីស្លាប់

ចូរយើងគិតអំពីទោសដែលយើងត្រូវទទួល ដែលជាបំណុលដែលយើងបានជំពាក់ព្រះ ដោយសារតែអំពើបាបរបស់យើង។ ដោយសារយើងមានបាបពីកំណើត បំណុលនៃអំពើបាបធំពេក សម្រាប់យើង បានជាយើងមិនអាចសងរួចដោយខ្លួនឯងបានឡើយ។

ប៉ុន្តែ ព្រះទ្រង់បានប្រទានផ្លូវមួយ។ ក្រឹត្យវិន័យរបស់ទ្រង់បានតម្រូវឲ្យមនុស្សបង់ថ្លៃលោះ បំណុលនៃអំពើបាបរបស់ខ្លួនឯង ប៉ុន្តែ ក្រឹត្យវិន័យទ្រង់ក៏អនុញ្ញាតឲ្យបុគ្គលម្នាក់បង់ថ្លៃលោះយើងផងដែរ។ ទោះជាយ៉ាងណាក៏ដោយ បុគ្គលនោះមិនអាចមានបំណុលផ្ទាល់ខ្លួនទេ ពោលគឺគាត់មិនមានអំពើបាបទាល់តែសោះ។

ហេតុនេះហើយ បានជាព្រះទ្រង់ចាត់ព្រះរាជបុត្រាទ្រង់ ព្រះយេស៊ូវគ្រីស្ទឲ្យយាងចុះមកបង់ថ្លៃលោះបំណុលនៃអំពើបាបនេះ។ ទ្រង់បានសុគតជំនួសយើង ដើម្បីឲ្យយើងអាចរួចពីទោសនៃអំពើបាប ដែលជាការស្លាប់អស់កល្បជានិច្ច។ កាលពីជាង២ពាន់ឆ្នាំមុន ព្រះយេស៊ូវបានយាងចុះមកផែនដី ដោយយកកំណើតជាមនុស្ស។ ទ្រង់ត្រូវបានគេធ្វើគុតនៅលើឈើឆ្កាង ដែលជាទោសសម្រាប់ឧក្រិដ្ឋជន ហើយក៏ត្រូវគេយកសពទ្រង់ទៅបញ្ចុះ បន្ទាប់ពីទ្រង់បានសុគត។

ទ្រង់អាចធ្វើការលះបង់ ដើម្បីលោះយើងឲ្យរួចពីបាប ព្រោះទ្រង់ជាព្រះ ហើយក៏ជាមនុស្សដែលគ្មានអំពើបាប។ ក្នុងនាមជាព្រះរាជបុត្រារបស់ព្រះ ទ្រង់ល្អឥតខ្ចោះ បានជាទ្រង់មិនមានអំពើបាប ដែលត្រូវទទួលខុសត្រូវដោយព្រះអង្គទ្រង់ឡើយ។ ទន្ទឹមនឹងនោះ ដោយសារទ្រង់បានសុគត ក្នុងលក្ខណៈជាមនុស្ស ទ្រង់បានធ្វើជាតំណាងឲ្យយើង ដោយទទួលទោសជំនួសយើងទាំងស្រុង។ ព្រះគម្ពីរបានចែង អំពីព្រះយេស៊ូវថា "ព្រះគ្រីស្ទទ្រង់បានលោះយើងរាល់គ្នា ឲ្យរួចពីសេចក្តីបណ្តាសារបស់ក្រឹត្យវិន័យ ដោយទ្រង់ត្រូវបណ្តាសាជំនួសយើងរាល់គ្នា"(កាឡាទី ៣:១៣)។

ដោយសារព្រះយេស៊ូវបានសុគត តើទ្រង់បានគេចផុតពីទោសនៃអំពើបាប ដែលជាសេចក្តីស្លាប់ដែរឬទេ? តើទ្រង់បានរំដោះយើងឲ្យរួចពីបណ្តាសា ឬទោស តាមក្រឹត្យវិន័យដោយរបៀបណា?

បន្ទាប់ពីទ្រង់បានសុគតបានបីថ្ងៃ ព្រះយេស៊ូវក៏បានមានព្រះជន្មរស់ឡើងវិញ ដោយបង្ហាញព្រះអង្គទ្រង់ ដល់មនុស្សរាប់រយនាក់ ដែលបានធ្វើជាសាក្សី មុនពេលទ្រង់យាងឡើងទៅនគរស្ថានសួគ៌វិញ។ ការមានព្រះជន្មឡើងវិញរបស់ទ្រង់ គឺបានបង្ហាញថា ទ្រង់បានលោះយើងឲ្យរួចពីអំណាចនៃអំពើបាបហើយ។ អំពើបាបនាំឲ្យមនុស្សទទួលសេចក្តីស្លាប់ ប៉ុន្តែ ព្រះយេស៊ូវបានឈ្នះអំពើបាបហើយ។ ការនេះបានបង្ហាញថា ការសុគតរបស់ទ្រង់ ជួសយើង ត្រូវបានព្រះទ្រង់ទទួលយកហើយ។

អ្នកប្រហែលជាសួរថា "តើការនេះមានប្រយោជន៍អ្វីខ្លះ ចំពោះខ្ញុំ?" ព្រះគម្ពីរបានប្រាប់យើងថា បើយើងទទួលការអត់ឱនទោស ពីព្រះយេស៊ូវ ដោយជឿថា ទ្រង់បានសុគតជួសយើង យើងនឹងបានទទួលការអត់ឱនទោស សម្រាប់អំពើបាបយើង ហើយយើងអាចទទួលការផ្សះផ្សាឲ្យជានឹងព្រះ។ កាលណាយើងបានទទួលជឿទ្រង់ហើយ យើងមិនមានទោសនៃអំពើបាបទៀតទេ បានជាយើងអាចអរសប្បាយនឹងទំនាក់ទំនងដ៏ឥតខ្ចោះជាមួយព្រះ ដូចដែលទ្រង់សព្វព្រះទ័យឲ្យមនុស្សមានតាំងពីដើមមក។

ជាងនេះទៅទៀត ទំនាក់ទំនងនេះ នឹងស្ថិតស្ថេរជារៀងរហូត។ គ្មានអ្វីអាចពង្រាត់យើងចេញពីព្រះបានទេ សូម្បីតែសេចក្តីស្លាប់ក៏ដោយ។

នេះជាក្តីសង្ឃឹមដែលយើងអាចមាន បើសិនជាយើងជឿថា ព្រះយេស៊ូវបានយាងចុះមកផែនដី ហើយសុគត ហើយបានមានព្រះជន្មរស់ឡើងវិញ ហើយបើយើងដើរតាមទ្រង់ ហើយទទួលជឿទ្រង់ ជាព្រះអម្ចាស់ និងព្រះសង្គ្រោះ។ ព្រះគម្ពីរបានចែងថា "ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម៉្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ"(យ៉ូហាន ៣:១៦)។




# ការទទួលយកការផ្ដល់ឲ្យរបស់ព្រះ

ព្រះវរបិតារបស់ព្រះយេស៊ូវ មិនគ្រាន់តែជាព្រះដែលល្អ ហើយមានក្ដីស្រឡាញ់ប៉ុណ្ណោះទេ តែទ្រង់ក៏ជាព្រះដែលប្រកបដោយព្រះគុណផងដែរ។ បានសេចក្ដីថា ទ្រង់មិនមានលក្ខខ័ណ្ឌ ឬការតម្រូវអ្វីសម្រាប់យើង ដើម្បីឲ្យអាចទទួលយកអំណោយនៃព្រះរាជបុត្រាទ្រង់ និងការអត់ឱនទោសឲ្យអំពើបាបរបស់យើងទេ។ មិនមែនទាល់តែអ្នកជា "មនុស្សល្អ" ឬបានខំប្រឹងធ្វើការល្អ ទើបអាចបានសេចក្ដីសង្គ្រោះនោះឡើយ។ អ្នកគ្រាន់តែត្រូវអនុញ្ញាតឲ្យព្រះជួយសង្គ្រោះអ្នកប៉ុណ្ណោះ។ អ្វីដែលអ្នកត្រូវធ្វើ គឺត្រូវទទួលស្គាល់ថា អ្នកបានធ្វើអំពើបាប ហើយត្រូវការការអត់ឱនទោសពីទ្រង់ និងជឿថា ព្រះយេស៊ូវបានយាងមកសុគត ជួសអ្នក ដើម្បីឲ្យអ្នកអាចជានឹងព្រះ ហើយដើរតាមទ្រង់ ដោយទទួលទ្រង់ជាព្រះអម្ចាស់ និងព្រះសង្គ្រោះរបស់អ្នក។ រឿងនេះគឺពិតជាសាមញ្ញណាស់។

(បើការនេះមានន័យចំពោះអ្នក ចូរគិតថា សេចក្ដីសង្គ្រោះរបស់ព្រះគឺជាអំណោយ ដែលព្រះបានប្រទានអ្នក ដោយគ្មានលក្ខខ័ណ្ឌ ប៉ុន្តែ អ្នកត្រូវទទួលស្គាល់ព្រះដែលជាអ្នកប្រទានអំណោយនោះ ហើយទទួលយកអំណោយនោះ ដោយស្ម័គ្រពីចិត្ត)។

ព្រះគម្ពីរបានចែងថា "បើមាត់អ្នកនឹងទទួលថ្លែងប្រាប់ពីព្រះអម្ចាស់យេស៊ូវ ហើយអ្នកជឿក្នុងចិត្តថា ព្រះបានប្រោសឲ្យទ្រង់រស់ពីស្លាប់ឡើងវិញ នោះអ្នកនឹងបានសង្គ្រោះពិត"(រ៉ូម ១០:៩)។

## តើរឿងនេះមានន័យយ៉ាងណាចំពោះអ្នក

មុនពេលអ្នកសម្រេចចិត្តទទួលអំណោយនៃសេចក្តីសង្គ្រោះរបស់ព្រះ អ្នកប្រហែលជាចង់សួរថា តើមានអ្វីកើតឡើង បន្ទាប់ពីខ្ញុំទទួលជឿទ្រង់ ?

ពេលដែលអ្នកទទួលជឿព្រះយេស៊ូវ មានការអស្ចារ្យជាច្រើនកើតឡើងចំពោះអ្នក។

ទីមួយ អ្នកនឹងទទួលការអត់ទោសពីព្រះ សម្រាប់អំពើបាបរបស់អ្នក។ ព្រះយេស៊ូវបានបង់ថ្លៃលោះអ្នក ធ្វើឲ្យអ្នកអាចជានឹងព្រះ បានជាទ្រង់អាចទទួលយកអ្នកទាំងស្រុង។ ជាងនេះទៅទៀត ទ្រង់បានសន្យាថា នឹងធ្វើឲ្យអ្នកក្លាយជាកូនប្រុសស្រីរបស់ទ្រង់ ហើយអ្នកអាចចូលទៅក្នុងព្រះវត្តមានទ្រង់ ដូចដែលអ័ដាម និងនាងអេវ៉ា ធ្លាប់បានធ្វើនៅក្នុងសួនច្បារអេដែន។ អ្នកអាចរស់នៅ ដូចជាកូនដែលដឹងច្បាស់ថា ឪពុកម្ដាយខ្លួនបានទទួលយកខ្លួនដោយសេចក្តីស្រឡាញ់។ ពោលគឺ អ្នកអាចរស់នៅ ដោយទំនុកចិត្តថា ព្រះទ្រង់បានស្រឡាញ់អ្នក ដោយមិនខ្វល់ថាអ្នកជានរណា ឬបានធ្វើអ្វី កាលពីមុនក៏ដោយ ឬក៏អ្នកមានភាពខ្វះចន្លោះយ៉ាងណាក៏ដោយ ព្រោះការសុគតរបស់ព្រះយេស៊ូវ បានបង់ថ្លៃលោះអ្នកឲ្យរួចពីអំពើបាបហើយ។ ទន្ទឹមនឹងនោះ ទ្រង់នឹងជួយអ្នក ឲ្យផ្លាស់ប្តូរផ្លូវនៃជីវិត ហើយរៀនរស់នៅ តាមខ្នាតគំរូដ៏បរិសុទ្ធរបស់ទ្រង់។



ទំនាក់ទំនងមួយនេះ នឹងបន្តជារៀងរហូត សូម្បីតែនៅពេលដែលយើងបានស្លាប់ហើយក៏ដោយ។ បានសេចក្តីថា អ្នកមិនចាំបាច់ត្រូវខ្លាចសេចក្តីស្លាប់ទៀតទេ។ អ្នកអាចរស់នៅ ដោយការដឹងច្បាស់ថា ការស្លាប់ខាងរូបកាយនឹងនាំឲ្យអ្នកចូលទៅរកព្រះវត្តមានព្រះដោយផ្ទាល់ គឺនៅកន្លែងដែលមានភាពឥតខ្ចោះ។

*ការនេះមានន័យថា អ្នកនឹងមានក្តីសង្ឃឹម។ អ្នកនឹងឈប់រស់នៅ ដោយគ្មានទិសដៅ ឬគ្មានន័យទៀតហើយ។*

(ព្រះគម្ពីរក៏បានប្រាប់យើងផងដែរថា ព្រះយេស៊ូវនឹងយាងត្រឡប់មកវិញ នៅថ្ងៃណាមួយ។ នៅថ្ងៃនោះ រូបកាយយើង ក៏នឹងរស់ឡើងវិញ ដូចទ្រង់ដែរ ហើយទ្រង់នឹងធ្វើឲ្យរូបកាយយើងមានភាពឥតខ្ចោះ។ ទ្រង់បានសន្យាថា នឹងជួយសង្គ្រោះជីវិតយើងទាំងមូល គឺមិនគ្រាន់តែសង្គ្រោះវិញ្ញាណយើងប៉ុណ្ណោះទេ។)

តាមពិត ទំនាក់ទំនងនេះអាចចាប់ផ្តើមនៅពេលនេះ ក្នុងជីវិតនេះ។

ការក្លាយជាគ្រីស្ទបរិស័ទ មិនមែនមានន័យថា បញ្ហារបស់អ្នកនឹងរលាយភ្លាមៗនោះឡើយ។ អ្នកនឹងនៅតែត្រូវប្រឈមមុខដាក់ឧបសគ្គប្រចាំថ្ងៃ និងទុក្ខលំបាកដទៃទៀត ដែលកើតចេញពីការរស់នៅ ក្នុងលោកិយដែលប្រេះបែក និងមានពេញដោយអំពើបាប។ ប៉ុន្តែ ឥឡូវនេះ មានភាពខុសប្លែកពីមុន ពោលគឺអ្នកអាចប្រឈមមុខនឹងឧបសគ្គទាំងនោះជាមួយព្រះ ដែលបានសន្យាថា នឹងគង់នៅជាមួយអ្នក ដោយគង់នៅក្នុងចិត្តអ្នក។ អ្នកនឹងអាចចូលទៅរកទ្រង់ នៅពេលណា និងនៅកន្លែងណាក៏បាន  ហើយទ្រង់នឹងយាងទៅជាមួយអ្នក ក្នុងដំណើរជីវិតរបស់អ្នក ដោយលើកទឹកចិត្ត ចម្រើនកម្លាំង រំឭក និងជួយអ្នកឲ្យក្លាយជាមនុស្សដែលទ្រង់សព្វព្រះទ័យ។ អ្នកអាចពឹងផ្អែកទៅលើព្រះ ដែលបានបង្កើតលោកិយ ហើយនៅគ្រប់គ្រងស្ថានការណ៍ទាំងអស់។

សរុបមក ការនេះមានន័យថា អ្នកនឹងមានក្តីសង្ឃឹម។ អ្នកនឹងឈប់រស់នៅ ដោយគ្មានទិសដៅ ឬគ្មានន័យទៀតហើយ ផ្ទុយទៅវិញ អ្នកនឹងបានរស់នៅ ដោយការដឹងច្បាស់ ដោយគោលបំណង និងការសន្យាថា នឹងបានជីវិតអស់កល្បជានិច្ច បន្ទាប់ពីអ្នកបានស្លាប់ខាងរូបកាយ។

# ការបោះជំហានទីមួយ >



## តើអ្នកបានត្រៀមខ្លួនដើរតាមព្រះយេស៊ូវ ហើយឬនៅ?

បើអ្នកបានត្រៀមខ្លួនហើយ សូមស្វែងរកន្លែងស្ងាត់ស្ងៀម ដើម្បីឲ្យអ្នកអាចទូលព្រះ ដោយផ្ទាល់ខ្លួនថា អ្នកព្រមទទួលការផ្តល់ឲ្យរបស់ទ្រង់ នូវការអត់ទោសបាប ដោយជឿលើព្រះរាជបុត្រាទ្រង់ ព្រះនាមយេស៊ូវ និងជឿថា ទ្រង់បានសុគត ជួសអ្នក នៅលើឈើឆ្កាង ហើយមានព្រះជន្មរស់ឡើងវិញ ហើយទូលទ្រង់ថា អ្នកបានត្រៀមខ្លួន ដើម្បីទទួលជឿទ្រង់ ជាព្រះអម្ចាស់ និងព្រះសង្គ្រោះ។ ព្រះទ្រង់តែងតែស្តាប់ជានិច្ច ដូចនេះ អ្វីដែលអ្នកត្រូវធ្វើ គឺត្រូវនិយាយទៅកាន់ទ្រង់ ដូចជាទ្រង់កំពុងនៅចំពោះមុខអ្នក។ បើសិនជាអាច សូមស្វែងរកមិត្តភក្តិដែលជាគ្រីស្ទបរិស័ទម្នាក់ ដើម្បីនាំអ្នកអធិស្ឋានយាងព្រះចូលគង់ក្នុងចិត្ត និងធ្វើជាសាក្សី។

សូមអធិស្ឋាន តាមលំនាំខាងក្រោមនេះ ដើម្បីអធិស្ឋានឲ្យចំចំណុច។ ពាក្យខាងក្រោម គ្រាន់តែជាលំនាំ អ្វីដែលសំខាន់នោះ គឺចិត្តរបស់អ្នក។ តើអ្នកបានអធិស្ឋានដោយស្មោះអស់ពីចិត្តប៉ុណ្ណា? នោះហើយជាអ្វីដែលសំខាន់ចំពោះព្រះ។

*ព្រះអង្គអើយ ទូលបង្គំដឹងថា ទូលបង្គំបានធ្វើបាបទាស់នឹងព្រះអង្គ។ ទូលបង្គំជឿថា ព្រះយេស៊ូវគឺជាព្រះរាជបុត្រាព្រះអង្គ ទ្រង់បានសុគតនៅលើឈើឆ្កាង ដើម្បីបង់ថ្លៃលោះទូលបង្គំ ឲ្យរួចពីបាប ហើយទ្រង់បានមានព្រះជន្មរស់ឡើងវិញ ដើម្បីជាភស្តុតាង បញ្ជាក់ថាទ្រង់ពិតជាបានប្រោសលោះទូលបង្គំមែន។*

*នៅពេលនេះ ទូលបង្គំសូមទទួលការអត់ទោសបាបទាំងស្រុង និងទទួលជីវិតអស់កល្បជានិច្ច។*
*ទូលបង្គំសូមទទួលជឿព្រះយេស៊ូវ ដែលជាអំណោយរបស់ព្រះអង្គ ដើម្បីទទួលសេចក្តីសង្គ្រោះ ហើយទូលបង្គំចង់ដើរតាមព្រះអង្គ។*
*ទូលបង្គំសូមអធិស្ឋានក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។ អាម៉ែន!*


មានអ្វីបន្ទាប់ទៀត >

បន្ទាប់ពីអ្នកបានអធិស្ឋានតាមលំនាំខាងលើហើយ ជាបន្តទៅនេះ អ្នកអាចចាប់ផ្ដើមរស់នៅ ក្នុងជីវិតថ្មីរបស់អ្នកជាមួយព្រះ ដោយលូតលាស់ ក្នុងទំនាក់ទំនងរបស់អ្នកជាមួយទ្រង់។ យើងខ្ញុំសូមលើកទឹកចិត្តអ្នកឲ្យអនុវត្តដូចខាងក្រោម :

(បើសិនជាអ្នកនៅមិនទាន់សម្រេចចិត្តទទួលជឿព្រះយេស៊ូវ សូមកុំបារម្ភ។ យើងខ្ញុំសូមលើកទឹកចិត្ត ឲ្យអ្នកស្វែងយល់បន្ថែមទៀត អំពីព្រះយេស៊ូវ ដើម្បីឲ្យអ្នកអាចធ្វើការសម្រេចចិត្ត ដោយគ្មានការស្ទាក់ស្ទើរ។ អ្នកនៅតែអាចអនុវត្តតាមចំណុចខាងក្រោម ដែលនឹងជួយឲ្យអ្នកស្វែងយល់បន្ថែមអំពីព្រះ)។

សូមចាប់ផ្ដើមអធិស្ឋាន។ ក្នុងនាមជាកូនព្រះ អ្នកអាចសន្ទនាជាមួយទ្រង់ នៅពេលណាក៏បាន។ ទ្រង់តែងតែស្ដាប់ ហើយទ្រង់ចូលចិត្តសន្ទនាជាមួយអ្នក។ អ្នកអាចទូលប្រាប់ទ្រង់ អំពីបញ្ហា ការភ័យខ្លាច និងតម្រូវការរបស់អ្នក ហើយទូលទ្រង់ អំពីការព្រួយបារម្ភ និងក្ដីអំណររបស់អ្នក។ សូមចំណាយពេលជជែកជាមួយព្រះជារៀងរាល់ថ្ងៃ ហើយអ្នកនឹងឃើញថា អ្នកកាន់តែជិតស្និទ្ធនឹងទ្រង់។

សូមចាប់ផ្ដើមអានព្រះគម្ពីរ។ ព្រះគម្ពីរគឺជាព្រះរាជសាររបស់ព្រះ សម្រាប់លោកិយ។ ព្រះគម្ពីរផ្ទុកទៅដោយអ្វីគ្រប់យ៉ាង ដែលព្រះសព្វព្រះទ័យឲ្យយើងដឹង ដោយរាប់បញ្ចូលទាំងផែនការ នៃសេចក្ដីសង្គ្រោះរបស់ទ្រង់ និងរបៀបដែលទ្រង់សព្វព្រះទ័យឲ្យយើងរស់នៅ ជាកូនរបស់ទ្រង់ ដែលបានទទួលការអត់ទោសបាប។ ទោះជាយ៉ាងណាក៏ដោយ អ្នកនឹងត្រូវការជំនួយ នៅក្នុងការអាន និងស្វែងយល់ព្រះបន្ទូលព្រះ។ អ្នកអាចសូមឲ្យមិត្តភក្តិដែលជាគ្រីស្ទបរិស័ទ ឬព្រះវិហារក្នុងតំបន់ជួយណែនាំអ្នក អំពីរបៀបចាប់ផ្ដើមអានព្រះបន្ទូលទ្រង់។

សូមចាប់ផ្ដើមចូលរួមកម្មវិធីក្នុងព្រះវិហារ។ ការក្លាយជាគ្រីស្ទបរិស័ទ គឺមានន័យថា អ្នកអាចចូលរួមក្នុងសហគមន៍នៃគ្រីស្ទបរិស័ទ ដែលមានសេចក្ដីជំនឿ និងសេចក្ដីសង្ឃឹមរួម ក្នុងព្រះយេស៊ូវ ដែលនាំឲ្យអ្នកទទួលការលើកទឹកចិត្តពីអ្នកដទៃ ហើយលើកទឹកចិត្តគេវិញផងដែរ ខណៈពេលដែលអ្នកបានថ្វាយបង្គំព្រះ ហើយបានរៀនសូត្របន្ថែមអំពីទ្រង់។ ក្នុងសហគមន៍នៃអ្នកជឿព្រះ ដែលបានទទួលការអត់ទោសបាបដូចគ្នា យើងអាចដើរជាមួយគ្នា នៅក្នុងដំណើររួមនៃសេចក្ដីជំនឿ លើព្រះយេស៊ូវ។ ដូចនេះ ប្រសិនបើអាច សូមព្យាយាមចូលរួម ក្នុងព្រះវិហារ។ អ្នកអាចសុំមិត្តភក្តិជាគ្រីស្ទបរិស័ទ ឲ្យនាំអ្នកទៅរកព្រះវិហារណាមួយក៏បាន។